**FOR IMMEDIATE RELEASE**
USAID Supporting Forests and Biodiversity Project
Phnom Penh Center, Building F, Room 588, Sothearos Blvd
Phone/ Fax: +855 (0)23 220 714, E-mail: infosfb@winrock.org

# MEDIA ADVISORY

# សៀវភៅកម្រងសត្វព្រៃដំបូងនិយាយអំពីសត្វព្រៃរបស់ប្រទេសកម្ពុជា នៅក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំព្រេចខេត្តមណ្ឌលគិរី

**ភ្នំពេញ ថ្ងៃទី២០កក្កដា២០១៧** -តាមរយៈគម្រោងគាំទ្រព្រៃឈើនិងជីវចម្រុះដែលគាំទ្រថវិកាដោយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ ដែលអនុវត្តដោយអង្គការ Winrock អន្តរជាតិ និងអង្គការ WWF-កម្ពុជា សហការជាមួយក្រសួងបរិស្ថាននឹងរៀបចំកម្មវិធី “ **ផ្សព្វផ្សាយឲ្យប្រើប្រាស់ជាផ្លូវការនូវសៀវភៅកម្រងសត្វព្រៃក្នុងដែនជម្រកសត្វព្រៃភ្នំព្រេច**” នៅថ្ងៃព្រហស្បតិ៍ទី២១កក្កដាចាប់ពីម៉ោង៩ព្រឹករហូត  ដល់ម៉ោង១១ព្រឹក នៅក្រសួងបរិស្ថានក្រោមអធិបតីចូលរួមដោយ ឯកឧត្តមបណ្ឌិត សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងតំណាងអង្គការ ស្ថាប័នដៃគូអភិវឌ្ឍន៍នានា។

កម្រងសៀវភៅនេះមាន៧៦ទំព័រដែលរៀបរាប់ជាសង្ខេបអំពីសាវតានៃអម្បូរសត្វព្រៃដ៏មានសារៈសំខាន់បំផុតដែលកំពុងរស់នៅក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំព្រេច ហើយសត្វព្រៃទាំងអស់សុទ្ធសឹងតែជាកម្រងរូបភាពស្អាតៗជាមួយនឹងព័ត៌មានទាំងឡាយនិយាយអំពីការងារអភិរក្សសត្វព្រៃ និងព្រៃឈើសម្រាប់មនុស្សនាពេលបច្ចុប្បន្ន និងជំនាន់ក្រោយ។

កម្មវិធីនេះរៀបចំដោយ អង្គការ WWF-កម្ពុជា រួមសហការជាមួយក្រសួងបរិស្ថាន និងអគ្គនាយកដ្ឋានរដ្ឋបាលការពារ  និងអភិរក្សធម្មជាតិ តាមរយៈគម្រោងគាំទ្រព្រៃឈើ  និងជីវចម្រុះ  ដែលគាំទ្រថវិកាដោយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID)។

###

## សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង

លោក អ៊ុន ចក្រី ប្រធានផ្នែកទំនាក់ទំនងនៃអង្គការ WWF-កម្ពុជា

ទូរស័ព្ទ ០១៧ ២៣៤ ៥៥៥

សារអេឡិចត្រូនិច chakrey.un@wwfgreatermekong.org